ធនាគារអភិវឌ្ឍន៍ជនបទ និងកសិកម្ម
AGRICULTURAL AND RURAL DEVELOPMENT BANK
ដើម្បីកសិករនិងអភិវឌ្ឍន៍សេដ្ឋកិច្ចសង្គម

# គម្រោងអាជីវកម្ម
# ដំណាំម្រះ



រៀបចំដោយ

**នាយកដ្ឋានគាំទ្រគោលនយោបាយរបស់រាជរដ្ឋាភិបាលនៃ**
**ធនាគារអភិវឌ្ឍន៍ជនបទ និងកសិកម្ម (ធ.អ.ជ.ក.)**

ខែសីហា ឆ្នាំ២០២៥

# មាតិកា

១- សេចក្តីផ្តើម ................................................ ១
២- ការអនុវត្តការដាំដុះ ................................................ ១
ក- ការរៀបចំដី និងប្រព័ន្ធស្រោចស្រព ................................................ ១
ខ- ល្បាយដីបណ្តុះកូន ................................................ ១
គ- ការជ្រើសរើសពូជ ................................................ ១
ឃ- វិធីដាំដុះ ................................................ ២
ង- ការថែទាំ ................................................ ២
ច- ការដាក់ជី ................................................ ២
ឆ- កត្តាចង្រៃ ................................................ ២
ជ- អាយុកាលដាំដុះ និងប្រមូលផល ................................................ ៣
៣- តម្រូវការទុនដំបូងក្នុងការដាំដុះម្រះ លើផ្ទៃដីទំហំ ១០ អា ................................................ ៤
៤- ការវិភាគសេដ្ឋកិច្ចលើការដាំដុះម្រះ លើផ្ទៃដីទំហំ ១០ អា ................................................ ៤
៥- លទ្ធភាពចំណេញផ្អែកលើនិន្នាការតម្លៃ លើផ្ទៃដីទំហំ ១០ អា ................................................ ៥
៦- ខ្សែច្រវាក់តម្លៃ ................................................ ៦
៧- កត្តាហានិភ័យ ................................................ ៦
៨- សេចក្តីសន្និដ្ឋាន ................................................ ៧

# គម្រោងអាជីវកម្មដាំដុះដំណាំម្រះ

## ១-សេចក្តីផ្តើម

ដើម្បីជាប្រយោជន៍ដល់កសិករដែលមានបំណងដាំដុះដំណាំម្រះសម្រាប់បង្កើនជីវភាពគ្រួសារ ខណៈដែលបន្លែប្រភេទនេះមានទីផ្សារល្អ ក្រុមការងារបច្ចេកទេសនៃធនាគារអភិវឌ្ឍន៍ជនបទ និងកសិកម្ម បានសិក្សារៀបចំគម្រោងអាជីវកម្មដាំដុះដំណាំម្រះ ដោយផ្តោតលើការដាំដុះតាមបច្ចេកទេសកសិកម្ម ការអនុវត្តជាក់ស្តែងរបស់ប្រជាកសិករ ការប្រើប្រាស់ជីធម្មជាតិ កាត់បន្ថយការប្រើប្រាស់ថ្នាំពុលគីមីកសិកម្មឱ្យនៅកម្រិតអប្បបរមា ទទួលបានទិន្នផលច្រើន គុណភាពខ្ពស់ និងមានសុវត្ថិភាពដល់អ្នកបរិភោគ។

គម្រោងអាជីវកម្មដំណាំម្រះនឹងអាចជួយដល់គ្រួសារកសិករឱ្យទទួលបានចំណូលល្អពីដំណាំនេះ តាមរយៈផ្តល់នូវចំណេះដឹង និងចំណេះធ្វើជាក់ស្តែង ជាមួយនឹងការបង្ហាញនូវការប្រើប្រាស់ទុន ការកត់ត្រាចំណូលចំណាយ ការវិភាគសេដ្ឋកិច្ច និងនិន្នាការតម្លៃម្រះ។

## ២-ការអនុវត្តការដាំដុះ

### ក. ការរៀបចំដី និងប្រព័ន្ធស្រោចស្រព÷

កសិករត្រូវភ្ជួរដីឱ្យម៉ដ្ឋល្អ រួចហាលដីទុករយៈពេលពី ១០ ទៅ ១៥ថ្ងៃ។ កសិករត្រូវប្រើប្រាស់ជីធម្មជាតិទ្រាប់បាតក្នុងបរិមាណ ៥០០ ទៅ ១,៥០០ គីឡូក្រាម /១,០០០ម៉ែត្រការ៉េ (តាមលទ្ធភាព និងគុណភាពដី) បន្ទាប់មកឆ្វូតពូនជារងដែលមានទទឹងរងខាងលើមានប្រវែង០.៦ម៉ែត្រ បាតរង០.៨ម៉ែត្រ កម្ពស់រង០.២-០.៣ម៉ែត្រ និងពីពាក់កណ្តាលរងមួយទៅពាក់កណ្តាលរងមួយប្រវែង១.៥ម៉ែត្រ ដោយដំឡើងនូវប្រព័ន្ធស្រោចស្រពដំណក់ទឹកពីលើរងបន្លែ និងគ្របដោយកៅស៊ូគ្របរង។

### ខ. ល្បាយដីបណ្តុះកូន ÷

ល្បាយដីបណ្តុះកូនត្រូវមានវត្ថុធាតុដើមសំខាន់ៗដូចជា÷ដីដំបូក ឬដីមានជីជាតិ១/៣ ធ្យូងអង្កាម១/៣ និងកំប៉ុស១/៣ ច្របល់ចូលគ្នា បន្ទាប់មកយកទៅលីង ឬចំហុយសម្លាប់មេរោគ និងគ្រាប់ស្មៅចង្រៃ។

### គ. ការជ្រើសរើសពូជ÷

កសិករអាចជ្រើសពូជម្រះមួយចំនួនដែលមានលក់នៅកម្ពុជា÷












**ឃ. វិធីដាំដុះ÷**

កសិករត្រូវយកកូនម្រះដែលបណ្តុះបានអាយុពី ១០ ទៅ ១៥ថ្ងៃ ពីថាសបណ្តុះមកដាំលើរងដែលបានគ្របកៅស៊ូរួចរាល់ ដោយដាំតែ១ជួរនៅលើរងក្នុងចន្លោះគុម្ពប្រវែង៦០-៨០ស.ម បង្គោលទ្រើងមានកម្ពស់២ម៉ែត្រ ចន្លោះបង្គោលមានប្រវែង២ម៉ែត្រ ប្រើប្រាស់សំណាញ់ទ្រើងបញ្ឈរភ្ជាប់បង្គោលទ្រើងនីមួយៗ និងអាចបន្ថែមសំណាញ់ទ្រើងជាដំបូល(តាមលទ្ធភាព) ឬប្រើប្រាស់ខ្សែអំបោះ ឬខ្សែខ្មៅជាទ្រើងដើម្បីងាយស្រួលគ្រប់គ្រង និងប្រមូលផល។




**ង. ការថែទាំ÷**

ត្រូវស្រោចទឹកក្នុងមួយថ្ងៃ២ដង គឺនៅពេលព្រឹក និងពេលរសៀល ផ្អែកលើសំណើមដីជាក់ស្តែង។ បន្ទាប់ពីដាំបានរយៈពេល៣ថ្ងៃឡើងទៅ ត្រូវមានកាលវិភាគប្រើប្រាស់ថ្នាំជីវសាស្ត្រ ថ្នាំពុលកសិកម្មសម្រាប់បង្ការជំងឺ និងសត្វល្អិតចង្រៃផ្សេងៗជាមុន។ ចាំបាច់ត្រូវសម្អាតស្មៅចង្រៃឱ្យបានស្អាត តាក់តែងមែកផ្នែកខាងក្រោម ស្លឹកចាស់ ដើម្បីកម្ចេចជម្រកសត្វល្អិតចង្រៃ និងជំងឺដំណាំ។ ដើម្បីការពារផ្លែម្រះពីសត្វល្អិតចង្រៃ កសិករអាចប្រើប្រាស់ក្រដាស ថង់ប្លាស្ទិក ឬក្រណាត់ស្បៃខ្ចប់ផ្លែម្រះ និងប្រើប្រាស់អន្ទាក់ក្លិន ឬអន្ទាក់ស្អិត ដើម្បីចាប់រុយទិចផ្លែ។

**ច. ការដាក់ជី÷**

ដំណាំម្រះក្រោយពេលដាំដុះរួច កសិករគប្បីមានកម្មវិធីប្រើប្រាស់ជី ដែលបរិមាណប្រែប្រួលទៅតាមស្ថានភាពលូតលាស់របស់ដំណាំ កសិករក៏អាចប្រើប្រាស់ប្រភេទជីទឹកនៅដំណាក់កាលលូតលាស់តាមប្រព័ន្ធដំណក់ទឹក និងការបាញ់បន្ថែមទៅលើស្លឹក។ សារធាតុជីចម្បងៗដូចជា÷អាសូត ផូស្វ័រ ប៉ូតាស្យូម កាល់ស្យូម ម៉ាញ៉េស្យូម និងសារធាតុបន្ថែមផ្សេងទៀត ដើម្បីជំរុញដល់ការដុះលូតលាស់ ភាពធន់ទៅនឹងជំងឺ សត្វល្អិត និងផ្កាផ្លែបានល្អ។

**ឆ. កត្តាចង្រៃ÷**

កសិករតែងជួបប្រទះនូវកត្តាចង្រៃដែលបំផ្លាញដំណាំម្រះមួយចំនួនដូចជា÷ អណ្តើកមាស ដង្កូវមីឡុន រុយទិចផ្លែ រុយស ទ្រីប ជំងឺផ្សិត និងជំងឺវីរុសជាដើម។



### ជ. អាយុកាលដាំដុះ និងប្រមូលផល÷

ម្រះអាចប្រមូលផលនៅអាយុ ៥០-៦០ថ្ងៃ ក្រោយពេលដាំកូន និងអាយុកាលដំណាំមានរយៈពេលពី ៣-៤ខែ ទិន្នផលគឺអាស្រ័យទៅលើប្រភេទពូជ លក្ខខណ្ឌដាំដុះ និងការថែទាំ។ ម្រះដែលមានតម្រូវការនៅលើទីផ្សារក្នុងប្រទេសកម្ពុជាគឺជាផ្លែចាស់ល្មម ដោយក្នុងមួយគីឡូក្រាមមានចំនួន ២-៤ផ្លែ។ ឧបករណ៍ប្រមូលផលមានដូចជា កន្ត្រៃ ឬកាំបិតមុត ដើម្បីកាត់ផ្ដាច់ទងមិនឱ្យប៉ះទង្គិចផ្លែ បន្ទាប់មកអាចច្រកក្នុងថង់ ឡាំងដែលធ្វើពីជ័រ ឬក្រដាសស្ងួត។





**៣-តម្រូវការទុនដំបូងក្នុងការដាំដុះម្រះ** លើផ្ទៃដីទំហំ ១០អា

| បរិយាយ | ចំនួនទឹកប្រាក់ (រៀល) |
|---|---|
| ចំណាយលើការដាំដុះ | 1,326,000 |
| ចំណាយលើប្រព័ន្ធស្រោចស្រព | 5,216,000 |
| សម្ភារផ្សេងៗ | 1,555,000 |
| **សរុប** | **8,097,000** |

**៤-ការវិភាគសេដ្ឋកិច្ចលើការដាំដុះដំណាំម្រះ** លើផ្ទៃដីទំហំ ១០អា

-បទពិសោធន៍÷ ការដាំដុះរបស់កសិករនៅឃុំល្វៀង ស្រុកត្បូងឃ្មុំ ខេត្តត្បូងឃ្មុំ

-ទិន្នផលមធ្យម÷ ២,៥០០ គ.ក/១០ អា

-តម្លៃជាមធ្យម÷ ១,២០០រៀល/គ.ក

-ចំនួនវគ្គក្នុងមួយឆ្នាំ÷ ៣វគ្គក្នុងមួយឆ្នាំ

ខាងក្រោមនេះគឺជាការវិភាគសេដ្ឋកិច្ចសម្រាប់ការដាំដុះដំណាំម្រះក្នុង១វគ្គ÷

| បរិយាយ | ឯកតា | ចំនួនឯកតា | តម្លៃ/ឯកតា (រៀល) | ទឹកប្រាក់ (រៀល) | ចំនួនវិលស់ | ទឹកប្រាក់សរុប(រៀល) |
|---|---|---|---|---|---|---|
| **១-ចំណូលពីការលក់** | គ.ក | 2,500 | 1,200 | 3,000,000 | | **3,000,000** |
| **២-ចំណាយសរុប = ចំណាយប្រែប្រួល + ចំណាយមិនប្រែប្រួល** | | | | | | **1,730,400** |
| **២.ក-ចំណាយប្រែប្រួលសរុប** | | | | | | **1,326,000** |
| ភ្ជួរដី និងលើករង | លើក | 3 | 30,000 | 90,000 | | 90,000 |
| ពូជ | កញ្ចប់ | 8 | 22,000 | 176,000 | | 176,000 |
| ជីកំប៉ុស | តោន | 1 | 135,000 | 135,000 | | 135,000 |
| ជីគីមីគ្រាប់ |ការ៉ុង | 1 | 170,000 | 170,000 | | 170,000 |
| ជីបំប៉នទឹក | ឈុត | 1 | 100,000 | 100,000 | | 100,000 |
| ថ្នាំសម្លាប់សត្វល្អិត + ជំងឺ | ឈុត | 1 | 100,000 | 100,000 | | 100,000 |
| ថ្លៃកម្មករដាំ និងថែទាំ | នាក់ | 15 | 30,000 | 450,000 | | 450,000 |
| ប្រេងម៉ាស៊ូត | លីត្រ | 30 | 3,500 | 105,000 | | 105,000 |

| ២.ខ-ចំណាយមិនប្រែប្រួលសរុប | | | | | | 404,400 |
|---|---|---|---|---|---|---|
| ប្រព័ន្ធទឹកមេ (ប្រើ៥ឆ្នាំ) | ឈុត | 1 | 256,000 | 256,000 | 15 | 17,067 |
| ប្រព័ន្ធទឹកស្រោចស្រព (ប្រើ២ឆ្នាំ) | ឈុត | 1 | 360,000 | 360,000 | 6 | 60,000 |
| ម៉ាស៊ីនបូមទឹក(១៥សេះ) | គ្រឿង | 1 | 1,600,000 | 1,600,000 | 30 | 53,333 |
| ធុងបាញ់ថ្នាំ (ប្រើ៣ឆ្នាំ) | ឈុត | 1 | 120,000 | 120,000 | 9 | 13,333 |
| កៅស៊ូគ្របរង(២វគ្គ) | ដុំ | 3 | 75,000 | 225,000 | 2 | 112,500 |
| ថាសបណ្ដុះកូន(៣វគ្គ) | បន្ទះ | 30 | 3000 | 90,000 | 3 | 30,000 |
| បង្គោលក្រាក់(ប្រើ១០ឆ្នាំ) | ដើម | 60 | 12,000 | 720,000 | 30 | 24,000 |
| ខ្សែលួស (ប្រើ៤ឆ្នាំ) | គីឡូ | 20 | 3,500 | 70,000 | 12 | 5,833 |
| ខ្សែជ័រខ្មៅ (ប្រើ២ឆ្នាំ) | គីឡូ | 20 | 4,000 | 80,000 | 6 | 13,333 |
| បង្គោលឫស្សី(ប្រើ២ឆ្នាំ) | បាច់ | 20 | 12,500 | 250,000 | 6 | 41,667 |
| អណ្ដូងទឹក (ប្រើ៣០ឆ្នាំ) | ឈុត | 1 | 3,000,000 | 3,000,000 | 90 | 33,333 |
| ៣-ចំណេញសរុប | | | | | | 1,269,600 |
| ថ្លៃដើមផលិត/គ.ក = ចំណាយសរុប/ទិន្នផលសរុប | | | | | | 692 |
| ចំណេញ/គ.ក = ចំណេញសរុប/ទិន្នផលសរុប | | | | | | 508 |

**៥-លទ្ធភាពចំណេញដោយផ្អែកលើនិន្នាការតម្លៃ ÷** (លើផ្ទៃដីជាំដុះ១០ អា)

-តម្លៃទាបបំផុត ៧០០៛/គ.ក

-តម្លៃខ្ពស់បំផុត ២,០០០៛/គ.ក

| ទិន្នផល គ.ក | តម្លៃ រៀល/គ.ក | ចំណូល រៀល | ចំណាយ រៀល | ចំណេញ-ខាត | |
|---|---|---|---|---|---|
| | | | | រៀល | % |
| 2,500 | 700 | 1,750,000 | 1,730,400 | 19,600 | 1.13% |
| 2,500 | 1,000 | 2,500,000 | 1,730,400 | 769,600 | 44.48% |
| 2,500 | 1,200 | 3,000,000 | 1,730,400 | 1,269,600 | 73.37% |
| 2,500 | 1,500 | 3,750,000 | 1,730,400 | 2,019,600 | 116.71% |
| 2,500 | 2,000 | 5,000,000 | 1,730,400 | 3,269,600 | 188.95% |

## ៦-ខ្សែច្រវាក់តម្លៃ ÷



**កសិករ**

ថ្លៃដើមផលិត÷ ៦៩២៛/គ.ក

ថ្លៃលក់នៅចម្ការ÷១,២០០៛/គ.ក

ចំណេញ÷៥០៨៛/គ.ក



**ឈ្មួញកណ្ដាល**

ថ្លៃដឹកជញ្ជូន÷ ១០០៛/គ.ក

ថ្លៃលក់បោះដុំ÷១,៥០០៛/គ.ក

ចំណេញ÷២០០៛/គ.ក



**អ្នកលក់រាយ**

ជួលតូបនិងខូចខាត÷៥០០៛/គ.ក

ថ្លៃលក់រាយ÷៣,០០០៛/គ.ក

ចំណេញ÷១,០០០៛/គ.ក

**បញ្ជាក់** ÷ឈ្មួញកណ្ដាល និងអ្នកលក់រាយ ជាអ្នកប្រមូលទិញយកទៅលក់នៅផ្សារក្នុងតំបន់។

## ៧-កត្តាហានិភ័យ ÷

តាមការសិក្សាផ្ទាល់លើការដាំដុះម្រះនៅឃុំល្វៀង ស្រុកត្បូងឃ្មុំ ខេត្តត្បូងឃ្មុំ យើងសង្កេតឃើញថា កសិករអាចនឹងជួបប្រទះនូវហានិភ័យមួយចំនួនជាយថាហេតុ ដូចជា÷

| ល.រ | ប្រភេទហានិភ័យ | ពិពណ៌នាហានិភ័យ | វិធានការ |
|---|---|---|---|
| ១ | **ហានិភ័យផលិតកម្ម** | ទិន្នផលធ្លាក់ចុះបណ្ដាលមកពីកត្តា÷<br>-ពូជ<br>-សត្វល្អិតចង្រៃ<br>-ជំងឺដំណាំ<br>-គុណភាពដី<br>-បម្រែបម្រួលអាកាសធាតុ | -គួរជ្រើសរើសពូជដែលចុះបញ្ជីកាត្រឹមត្រូវ អាចធន់នឹងបម្រែបម្រួលអាកាសធាតុ និងផ្ដល់ទិន្នផលខ្ពស់<br>-គួរប្រើប្រាស់វិធានការការពារដំណាំ និងមានកាលវិភាគប្រើប្រាស់ថ្នាំពុលកសិកម្មឱ្យបានត្រឹមត្រូវសម្រាប់កម្ចាត់សត្វល្អិតចង្រៃ និងជំងឺលើដំណាំ<br>-ប្រើប្រាស់ថ្នាំជីវសាស្ត្រ មុនពេលចាប់ផ្ដើមដាំដុះ<br>-ការពារផ្លែម្រះដោយខ្ចប់នឹងក្រដាស ថង់ផ្លាស្ទិក ឬក្រណាត់ស្បៃ<br>-សិក្សាការកែប្រែគុណភាពដី និងការគ្រប់គ្រងជីឱ្យស្របតាមតម្រូវការរបស់ដំណាំ |

| | | | |
|---|---|---|---|
| ២ | **ហានិភ័យទីផ្សារ** | ក្នុងខែវិច្ឆិកា-កុម្ភៈ&ឧសភា-តុលា តម្លៃផ្លែម្រះធ្លាក់ចុះដោយសារ÷<br>-អាកាសធាតុអំណោយផល<br>-កសិករដាំដុះតាមផ្ទះច្រើន | -ពង្រីកបណ្ដាញទីផ្សារឱ្យបានច្រើន និងតាមដានព័ត៌មានទីផ្សារជាប្រចាំ<br>-ចងក្រងក្រុមផលិត ដើម្បីធ្វើកិច្ចព្រមព្រៀងទិញ-លក់ និងធ្វើផែនការផលិតតាមកិច្ចសន្យា<br>-ដាំដំណាំចម្រុះឱ្យបានច្រើន ជាជាងដំណាំតែមួយមុខ<br>-ស្វែងរកព័ត៌មាននៃការដាំដុះនៅតំបន់ផ្សេងៗ ដើម្បីជ្រើសរើសមុខដំណាំសម្រាប់ដាំដុះ |

## ៨-សេចក្ដីសន្និដ្ឋាន

ដំណាំម្រះងាយស្រួលដាំដុះថែទាំ អាចលូតលាស់បានល្អ ស្ទើរតែគ្រប់ប្រភេទដី ធន់ជាមួយកម្ដៅព្រះអាទិត្យ ភ្លៀងធ្លាក់ច្រើន និងផ្ដល់ផលរយៈពេលយូរ។ ទីផ្សារផ្លែម្រះធំទូលាយ ព្រោះឈ្មួញតែងតែប្រមូលទិញដើម្បីលក់ចែកចាយបន្តទៅទីផ្សារទូទៅ និងផ្សារទំនើប។ កសិករលក់ផ្លែម្រះបោះដុំចេញពីចម្ការក្នុងតម្លៃចន្លោះពី១,០០០៛-១,២០០៛/គ.ក ដែលអាចឱ្យកសិករ និងឈ្មួញមានលទ្ធភាពចំណេញ។

ការស្វែងយល់អំពីបច្ចេកទេសកសិកម្មថ្មីៗ ការអនុវត្តការដាំដុះដែលសមស្របទៅនឹងបម្រែ-បម្រួលអាកាសធាតុ ព្រមទាំងមានបណ្ដាញព័ត៌មានគ្រប់គ្រាន់ អាចជួយឱ្យកសិករស្វែងរកទីផ្សារបានទូលំទូលាយក្នុងការបង្កើនប្រាក់ចំណូលពីការដាំដុះដំណាំម្រះផងដែរ។ ម្រះគឺជាដំណាំដ៏សំខាន់មួយ ក្នុងការចូលរួមចំណែករក្សាសន្តិសុខស្បៀងសម្រាប់គ្រួសារកសិករ និងជាប្រភពអាហារូបត្ថម្ភដ៏សម្បូរបែបក្នុងការលើកកម្ពស់សុខុមាលភាពប្រជាជនកម្ពុជា។

ប្រភពសិក្សា÷

-កសិករមានបទពិសោធន៍ជោគជ័យក្នុងការដាំដំណាំម្រះនៅឃុំល្វៀង ស្រុកត្បូងឃ្មុំ ខេត្តត្បូងឃ្មុំ

-ឯកសារក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ

-https://www.shutterstock.com/search/bitter-gourd-disease?image_type=photo&page=2